# ឯកសារព័ត៌មានអំពីក្រមចំណីអាហារ #26

*ប្រការដែលអ្នកគួរយល់ដឹងអំពីក្រម*

WWW.HEALTHOREGON.ORG
/FOODSAFETY

### ហេតុផលសុខភាពសាធារណៈ៖

**3-202.17 សត្វទឹកមានសំបកដែលបានបកសំបក, ការវេចខ្ចប់និងការសម្គាល់។**
ប្រដាប់ផ្ទុកធ្វើពីប្លាស្ទិចសម្រាប់ផលិតផលដែលបានបកសំបកមានព័ត៌មានជាក់លាក់ទាក់ទងនឹងប្រភពនៃសត្វទឹកមានសំបកដូចដែលបានតម្រូវដោយមគ្គុទេសក៍សម្រាប់ការគ្រប់គ្រងសត្វទឹកមានសំបកអម្បូរខ្យងរបស់ NSSP។ ប្រដាប់ផ្ទុកទាំងនេះត្រូវតែមិនប្រមូលមកវិញ ដើម្បីកុំឱ្យមានលទ្ធភាពដែលអ្នកវេចខ្ចប់សត្វទឹកមានសំបកយកមកប្រើវិញបន្តទៀត ដែលអាចធ្វើឱ្យផលិតផលដែលបានបកសំបកមិនត្រូវនឹងស្លាកសម្គាល់។

**3-202.18 ការសម្គាល់/អត្តសញ្ញាណសត្វទឹកជាប់សំបក។**
ការសម្គាល់/អត្តសញ្ញាណប្រភពត្រឹមត្រូវនៃតំបន់ប្រមូលផល អ្នកប្រមូលផល និងអ្នកចែកចាយត្រូវតែមាននៅលើស្លាកសម្គាល់ ដើម្បីក្នុងករណីដែលមានការផ្ទុះជំងឺឆ្លងតាមសត្វទឹកមានសំបកកើតឡើង គេមានព័ត៌មានដើម្បីពន្លឿនការស៊ើបអង្កេតផ្នែករោគរាតត្បាត និងវិធានការតាមបទប្បញ្ញត្តិ។

**3-202.19 សត្វទឹកជាប់សំបក លក្ខខណ្ឌ។**
សត្វទឹកជាប់សំបកដែលកខ្វក់ ខូចរូបរាង ឬងាប់ អាចចម្លងភាពកខ្វក់ និងធ្វើឱ្យថយគុណភាពសត្វទឹកជាប់សំបកដែលនៅរស់និងមានសុខភាពល្អ និងបណ្ដាលឱ្យមានជំងឺឆ្លងតាមអាហារ។

**3-203.11 សត្វទឹកមានសំបកអម្បូរខ្យងប្រដាប់ផ្ទុកដើមដំបូង។**
ការញែកឡូត៍មានសារៈសំខាន់ណាស់ចំពោះការដាក់ដាច់ដោយឡែកនូវសត្វទឹកមានសំបកដែលជាប់ពាក់ព័ន្ធនឹងការផ្ទុះជំងឺ និងការតាមដានពួកវាទៅរកប្រភពរបស់ពួកវា។ បើសិនជាឡូត៍លាយឡំគ្នានៅកន្លែងលក់រាយ នោះភាពអាចតាមដានបាននិងចុះខ្សោយ ហើយឫសគល់នៃបញ្ហាអាចនឹងនៅតែរកមិនឃើញ។

**3-203.12 សត្វទឹកជាប់សំបក ការរក្សាអត្តសញ្ញាណ។**
កំណត់ត្រាត្រឹមត្រូវដែលត្រូវបានរក្សាទុកតាមរបៀបមួយដែលអាចឱ្យគេងាយស្រួលផ្គូផ្គងពួកវាជាមួយនឹងឡូត៍នីមួយៗនៃសត្វទឹកជាប់សំបក ផ្ដល់ជាយន្តការចម្បងសម្រាប់ការតាមដានសត្វទឹកជាប់សំបកទៅរកប្រភពដើមរបស់វា។ ត្រូវតែរក្សាកំណត់ត្រារយៈពេល 90 ថ្ងៃ ដើម្បីទុកពេលឱ្យការបង្កមេរោគរលាកថ្លើមប្រភេទ A ដែលមានរយៈពេលបង្ករោគយូរជាងគួរឱ្យកត់សម្គាល់ជៀបនឹងជំងឺឆ្លងតាមសត្វទឹកមានសំបកនោះ លេចឡើងកាន់តែច្បាស់។ “រយៈពេល” 90 ថ្ងៃ ចាប់ផ្ដើមនៅពេលដែលគេយកសត្វទឹកជាប់សំបកចេញអស់ពីប្រដាប់ផ្ទុក។

## សត្វទឹកមានសំបកអម្បូរខ្យងដែលនៅ

វាសំខាន់ណាស់ដែលត្រូវចាត់ចែង និងរក្សាទុកសត្វទឹកមានសំបកអម្បូរខ្យង (អយស្ទ័រ, លៀសសមុទ្រ, គ្រំ និងងាវ) ឱ្យបានត្រឹមត្រូវនៅក្នុងកន្លែងសេវាកម្មចំណីអាហារ ដើម្បីបង្ការជំងឺឆ្លងតាមអាហារដែលអាចមាន។ ត្រូវរក្សាកំណត់ត្រាសម្រាប់ផលិតផលសត្វទឹកមានសំបក ក្នុងករណីដែលមានការផ្ទុះជំងឺ ដើម្បីតាមដានផលិតផលត្រឡប់ទៅរកតំបន់ប្រមូលផលលក្ខណៈពាណិជ្ជកម្ម។

និយមន័យនានាដែលពាក់ព័ន្ធនឹងសត្វទឹកមានសំបកនៅក្នុងវិធានអនាម័យចំណីអាហារមាន៖ **"សត្វទឹកមានសំបកអម្បូរខ្យង"** មានន័យថាជាប្រភេទសត្វដែលអាចបរិភោគបានដូចជាអយស្ទ័រ លៀសសមុទ្រ គ្រំ ឬផ្នែកដែលបរិភោគបានរបស់វា ដែលស្រស់ ឬបង្កក លើកលែងតែនៅពេលដែលផលិតផលពីងាវមានតែសាច់ដុំទាញដែលបានបកសំបកប៉ុណ្ណោះ។ **"សត្វទឹកជាប់សំបក"** មានន័យថា សត្វទឹកមានសំបកអម្បូរខ្យងដែលនៅ និងមិនទាន់បកសំបក។
**"សត្វទឹកមានសំបកដែលបានបកសំបក"** មានន័ថាសត្វទឹកមានសំបកអម្បូរខ្យងដែលបានយកសំបកមួយចំហៀងឬទាំងពីរចេញ។




***ឧទាហរណ៍អំពី *ស្លាកអ្នកចែកចាយដែលមានព័ត៌មានចាំបាច់តិចបំផុត។***

**ប្រភពនិងការដាក់ស្លាក៖**
សត្វទឹកមានសំបកទាំងអស់ត្រូវតែមានប្រភពដែលមានការអនុម័តដែលមាននៅក្នុងបញ្ជីក្រុមហ៊ុនដឹកជញ្ជូនសត្វទឹកមានសំបកដែលមានការបញ្ជាក់អន្តររដ្ឋ (ICSS)។

ហាងលក់គ្រឿងធ្វើម្ហូបមិនមែនជាប្រភពដែលត្រូវបានអនុម័តដើម្បីឱ្យយកសត្វទឹកមានសំបកទៅប្រើប្រាស់នៅតាមភោជនីយដ្ឋានទេ។



***ត្រូវរក្សាទុកសត្វទឹកមានសំបកនៅក្នុងប្រដាប់ផ្ទុកដើមដំបូងដោយមានស្លាករបស់វា***

សត្វទឹកមានសំបកដែលបានបកសំបកដែលនៅ ត្រូវតែនៅក្នុងកញ្ចប់ដែលមិនប្រមូលមកវិញដែលមានស្លាកអាចអានបានដែលមានឈ្មោះ អាសយដ្ឋាន និងលេខវិញ្ញាបនបត្ររបស់ក្រុមហ៊ុនបកសំបក ក្រុមហ៊ុនវេចខ្ចប់ ឬក្រុមហ៊ុនវេចខ្ចប់ឡើងវិញនូវសត្វទឹកមានសំបកអម្បូរខ្យង និងថ្ងៃ "ផុតកំណត់លក់" ឬថ្ងៃ "ផុតកំណត់ប្រើ" សម្រាប់កញ្ចប់ដែលតិចជាងកន្លះហ្គាឡុង ឬកាលបរិច្ឆេទបកសំបកសម្រាប់កញ្ចប់កន្លះហ្គាឡុងឡើងទៅ។

**ការរក្សាទុក៖**
ផលិតផលសត្វទឹកមានសំបកទាំងអស់ត្រូវតែរក្សាទុកនៅសីតុណ្ហភាពក្រោម 41F និងខាងលើ/ឆ្ងាយពីប្រភេទអាហារពីសត្វដែលនៅផ្សេងទៀត។ មិនអាចបញ្ចូលសត្វទឹកជាប់សំបកជាមួយសត្វទឹកជាប់សំបកមកពីឡូត៍ តំបន់ចិញ្ចឹម

លេខកូដប្រដាប់ផ្ទុក និង/ឬ កាលបរិច្ឆេទបកសំបកផ្សេងគ្នាទេ។

ត្រូវរក្សាឡូត៍នីមួយៗនៃសត្វទឹកជាប់សំបកដោយឡែកពីឡូត៍ចាស់/ថ្មី។ មិនត្រូវប្រើកន្សែងក្រណាត់ដើម្បីគ្របសត្វទឹកមានសំបកទេ។ FDA ណែនាំឱ្យគ្របសត្វទឹកជាប់សំបកដោយទឹកកកនៅក្នុងថាសដែលបង្ហូរទឹកចេញដោយខ្លួនឯង។

សត្វទឹកមានសំបកដែលនៅមិនមានការតម្រូវឱ្យដាក់ស្លាកកាលបរិច្ឆេទទេ។

ត្រូវពិនិត្យមើលសត្វទឹកជាប់សំបកនៅពេលទទួល




*លក្ខខណ្ឌទាមទារសម្រាប់ការរក្សាកំណត់ត្រាមិនអនុវត្តចំពោះសត្វទឹកមានសំបកដែលបានវេចខ្ចប់បែបសុញ្ញាកាសសម្រាប់លក់ទេ។*

ហើយត្រូវយកសត្វទឹកមានសំបកដែលងាប់ ឬសត្វទឹកជាប់សំបកដែលបែកសំបកចេញរាល់ថ្ងៃ។

**ការរក្សាអត្តសញ្ញាណសត្វទឹកមានសំបក៖** ត្រូវតែទុកស្លាកបន្ទោង ឬស្លាកជាមួយនឹងប្រដាប់ផ្ទុកដើមដំបូងរហូតដល់វាទទេ។ត្រូវតែទុកស្លាកបន្ទោង ឬស្លាកជាមួយនឹងប្រដាប់ផ្ទុកដើមដំបូងរហូតដល់វាទទេ។ បន្ទាប់ពីប្រដាប់ផ្ទុកទទេហើយ ត្រូវសរសេរកាលបរិច្ឆេទចុងក្រោយនៃការប្រើប្រាស់នៅលើស្លាកបន្ទោង/ស្លាក រួចទុកវារយៈពេល 90 ថ្ងៃសម្រាប់សត្វទឹកមានសំបកដែលផ្តល់ជូនទាំងនៅឆៅ ឬមិនទាន់ឆ្អិន។

រក្សាស្លាកបន្ទោង/ស្លាកតាមលំដាប់ថ្ងៃខែ ដើម្បីងាយស្រួលរកពួកវាក្នុងករណីប្រមូលមកវិញ។ សម្រាប់ផលិតផលដែលបានបកសំបកដែលផ្តល់ជូនមិនទាន់ឆ្អិន គម្របត្រូវដាក់កាលបរិច្ឆេទ និងរក្សាទុករយៈ 90 ថ្ងៃដែរ។

**ការផ្តល់ឱវាទដល់អតិថិជន៖**
ផលិតផលសត្វទឹកមានសំបកដែលឆៅ ឬមិនទាន់ឆ្អិនត្រូវតែមានការផ្តល់ឱវាទដល់អតិថិជននៅលើម៉ឺនុយដើម្បីជូនដំណឹងដល់អតិថិជន។ សូមមើលឯកសារព័ត៌មាន #6 សម្រាប់ព័ត៌មានបន្ថែម។



*មិនត្រូវប្រើឡើងវិញនូវសំបកពីផលិតផលនានាដូចជាអយស្ទ័រទេ*




_ឧទាហរណ៍អំពី *ស្លាកអ្នកប្រមូលផលដែលមានព័ត៌មានចាំបាច់_

*ស្លាកបន្ទោងនេះ ត្រូវបានទុកមិនបកប្រែដោយចេតនា